ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

*ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៦*

## កម្មវិធី Taste of Australia ឆ្នាំ២០២៦ - អបអរផលិតផលប្រណីតរបស់អូស្ត្រាលីនៅកម្ពុជា

ស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានរៀបចំកម្មវិធី Taste of Australia ឆ្នាំ២០២៦ ប្រកបដោយមោទនភាព ដោយបាននាំយកនូវអាហារ ឈីស និងស្រារបស់អូស្ត្រាលី ក្នុងរាត្រីមួយនៃការអបអររសជាតិ និងអាហារដែលមានគុណភាពខ្ពស់។

ព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ ដោយបានទទួលស្វាគមន៍ និងជួបជុំតំណាងជាន់ខ្ពស់ពីរាជរដ្ឋាភិបាល វិស័យធុរកិច្ច បដិសណ្ឋារកិច្ច ឧស្សាហកម្មអាហារ និងភេសជ្ជៈ ប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងអ្នកបង្កើតមាតិកាល្បីៗនៅក្នុងវិស័យម្ហូបអាហាររបស់កម្ពុជា។

មុខម្ហូបនៅក្នុងកម្មវិធី បានបង្ហាញនូវគ្រឿងផ្សំជាច្រើនរបស់អូស្ត្រាលី រួមមាន ត្រីធូណាមកពីភាគខាងត្បូងប្រទេសអូស្ត្រាលី បង្កងមកពីឈូងសមុទ្រ Spencer សាច់ជ្រូកផ្អែមមកពីតំបន់ Bayron Bay សាច់គោផ្ទែកថ្ពាល់ (Wagyu Beef Cheek) ពីតំបន់ Darling Downs នៃរដ្ឋ Queensland ព្រមទាំង Finger Limes និងស្លឹក Lemon Myrtle មានក្នុងបង្អែម Pavlova ដែលបង្ហាញអំពីរសជាតិដើមនៃអូស្ត្រាលី។

ភ្ញៀវកិត្តិយសក៏បានភ្លក់រសជាតិឈីស Jindi Camembert ពីរដ្ឋ Victoria សូកូឡា Haigh ពីទីក្រុង Adelaide ស្រា Lark Whiskey ពីរដ្ឋ Tasmania និងស្រា Four Pillars Gin ពីតំបន់ Healesville រដ្ឋ Victoria ដែលបង្ហាញអំពីភាពសម្បូរបែបនៃផលិតផលអាហារ និងភេសជ្ជៈប្រណីតរបស់អូស្ត្រាលី។

កម្មវិធី Taste of Australia ឆ្នាំនេះ ក៏បានពង្រីកវិសាលភាពលើសពីតុអាហារផងដែរ។ ចាប់ពីថ្ងៃទី ២៦ ខែមិថុនា ដល់ថ្ងៃទី ២៥ ខែកក្កដា ស្ថានទូតអូស្ត្រាលីសហការជាមួយនឹងផ្សារទំនើបឡាក់គី លើយុទ្ធនាការ Taste of Australia នៅទូទាំង ១០ សាខារបស់ផ្សារ ដើម្បីផ្តល់ឱកាសឱ្យសារធារណជនអាចស្វែងរក និងស្គាល់ផលិតផលអូស្ត្រាលីជាច្រើនមុខ ដែលមានលក់នៅទីនេះផ្ទាល់ក្នុងប្រទេសកម្ពុជា។

កម្មវិធី Taste of Australia ឆ្នាំ២០២៦ គឺជាផ្នែកមួយនៃកិច្ចប្រឹងប្រែងបន្តបន្ទាប់របស់ស្ថានទូតក្នុងការដាក់បង្ហាញផលិតផលលំដាប់ពិភពលោករបស់អូស្ត្រាលី និងពង្រឹងចំណងទំនាក់ទំនងពាណិជ្ជកម្មទ្វេរភាគីរវាងអូស្ត្រាលី និងកម្ពុជាឱ្យកាន់តែស៊ីជម្រៅ។

ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖ «កម្មវិធី Taste of Australia គឺជាការចែករំលែកនៃភាពសម្បូរបែប និងគុណភាពនៃផលិតផលអូស្ត្រាលីទៅកាន់មិត្តភក្តិរបស់យើងនៅក្នុងប្រទេសកម្ពុជា។ ចាប់ពីកសិដ្ឋាន និងការនេសាទ រហូតដល់ចំការទំពាំងបាយជូរ និងអ្នកផលិតកែច្នៃដោយដៃផ្ទាល់ របស់យើង ប្រទេសអូស្ត្រាលីផ្តល់ជូននូវផលិតផលដែលល្បីល្បាញទូទាំងពិភពលោក ដោយសារគុណភាពលំដាប់ខ្ពស់ សុវត្ថិភាព និងប្រកបទៅដោយចីរភាព។»

«យើងមានសេចក្តីរីករាយដែលផលិតផលទាំងនេះជាច្រើន មានលក់ជាស្រេចនៅក្នុងប្រទេសកម្ពុជា ដែលធ្វើឱ្យប្រជាជនកម្ពុជាងាយស្រួល និងរីករាយជាមួយរសជាតិនៃផលិតផលអូស្ត្រាលី។»

«កម្ពុជានាំចូលផលិតផលកសិកម្ម និងអាហារពីអូស្ត្រាលីក្នុងតម្លៃប្រមាណ ១០០លានដុល្លារអូស្ត្រាលីជារៀងរាល់ឆ្នាំ រួមមាន ផលិតផលទឹកដោះគោ ៣២ លានដុល្លារអូស្ត្រាលី សាច់គោ ១៧ លានដុល្លារអូស្ត្រាលី និងផលិតផលគ្រាប់ធញ្ញជាតិ ២៥ លានដុល្លារអូស្ត្រាលី។»

លោកស្រី Emma McDonald ស្នងការជាន់ខ្ពស់ផ្នែកពាណិជ្ជកម្ម និងវិនិយោគអូស្ត្រាលីប្រចាំនៅវៀតណាម និងកម្ពុជា បានមានប្រសាសន៍ថា «កម្ពុជាគឺជាទីផ្សារមួយដែលកំពុងតែមានសារៈសំខាន់សម្រាប់ការនាំចេញអាហារ និងកសិកម្មរបស់អូស្ត្រាលី គាំទ្រដោយតម្រូវការកាន់តែកើនឡើងរបស់អ្នកប្រើប្រាស់ ចំពោះផលិតផលលំដាប់ប្រណីត និងមានគុណភាពខ្ពស់។»

«កម្មវិធី Taste of Australia ផ្តល់ឱកាសមួយក្នុងការភ្ជាប់ទំនាក់ទំនងរវាងអ្នកប្រើប្រាស់ និងអាជីវកម្មកម្ពុជា ជាមួយអ្នកផលិតអូស្ត្រាលី ហើយបានបង្ហាញពីសក្តានុពលក្នុងការបន្តពង្រឹងទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីរបស់យើងបន្ថែមទៀត។»

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖** [Media.Cambodia@dfat.gov.au](mailto:Media.Cambodia@dfat.gov.au)